## គោលការណ៍ដែនដី (territorial principle)

គោលការណ៍នេះ នាំឲ្យបង្កើតមានយុត្តាធិការ លើបទល្មើសកើតមាននៅក្នុងដែនដីរបស់រដ្ឋ។ វាមានមូលដ្ឋានមកពីអធិបតេយ្យដែនដីរបស់រដ្ឋ។ គោលការណ៍នេះ មានលក្ខណៈចម្បងជាងគេ ពាក់ព័ន្ធនឹងយុត្តាធិការ និងមានប្រវត្តិជាយូរមកហើយ។ គេសន្មត់ថា រដ្ឋទាំងអស់មានយុត្តាធិការលើអ្វី (បទល្មើស) ដែលកើតមាននៅក្នុងដែនដីរបស់ខ្លួន លើកលែងមានច្បាប់ ឬសន្ធិសញ្ញាចែងច្បាស់ផ្ទុយពីនេះ។

ផ្អែកតាមគោលការណ៍នេះ វាមិនចាំបាច់ដែលបទល្មើសទាំងស្រុង ត្រូវបានប្រព្រឹត្តនៅក្នុងដែនដីទេ ប្រសិនបើធាតុផ្សំណាមួយនៃបទល្មើស ត្រូវបានបំពេញក្នុងដែនដីឬ ផលវិបាកនៃបទល្មើសកើតមានក្នុងដែនដី ទោះអំពីល្មើសផ្តើមពីដែនដីរដ្ឋផ្សេងក្តី ដែលតុលាការនឹងមានយុត្តាធិការ។

អ្វីជាបញ្ហាគឺថាតើអ្វីជាដែនដី? បទល្មើស ឬផលវិបាកកើតមានក្នុងលំហសមុទ្រ (maritime space) លើ board កប៉ាល់ យន្តហោះ ដែលចុះបញ្ជីក្នុងរដ្ឋ ត្រូវបានចាត់ថាក្នុងដែនដី។

ក្រៅពីយុត្តាធិការ មានចែងក្នុងបទប្បញ្ញត្តិ រដ្ឋមានយុត្តាធិការក្នុងការអនុវត្តផ្តាច់មុខ (exclusive) ដែលនេះក្នុងខ្លឹមសារថា រដ្ឋដែនដីមានសិទ្ធិបង្ខំឲ្យមានការអនុវត្តតាមច្បាប់ និងវិធានរបស់ខ្លួន (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 531-532)។